ខែតុលា-ធ្នូ ឆ្នាំ២០២១
លេខចេញផ្សាយ ០២

ខេមបូចា
CamboJA

សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា
*Cambodian Journalists Alliance Association*



# របាយការណ៍ឃ្លាំមើល
# ប្រចាំត្រីមាសស្តីពី
# ស្ថានភាព
# អ្នកសារព័ត៌មាន
# នៅកម្ពុជា

គាំទ្រមូលនិធិដោយ
Sweden
Sverige

របាយការណ៍ប្រចាំត្រីមាសនេះ គឺជាផ្នែកមួយនៃការបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខេមបូចាក្នុងការឃ្លាំមើលនិងតស៊ូមតិ ដើម្បីសេរីភាពសារព័ត៌មាននៅកម្ពុជា។ របាយការណ៍នេះមានបញ្ចូលការដកស្រង់សង្ខេបនៃករណីនិងព័ត៌មានបច្ចុប្បន្នភាពដែលទាក់ទងនឹងសេរីភាពសារព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិរបស់អ្នកសារព័ត៌មានចាប់ពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០២១។

ការវិវឌ្ឍមួយក្នុងចំណោមការវិវឌ្ឍដ៏គួរឲ្យកត់សម្គាល់បំផុត ដែលយើងបានឃ្លាំមើលនៅក្នុងត្រីមាសនេះ គឺការឃាត់ខ្លួនអ្នកសារព័ត៌មានពីររូបដែលចុះយកព័ត៌មានអំពីការតវ៉ាដីធ្លីនៅខេត្តកំពត។ នគរបាលបានចោទប្រកាន់អ្នកសារព័ត៌មានទាំងពីរពីបទញុះញង់បង្កឲ្យមានភាពវឹកវរក្នុងសង្គម និងបទបរិហារកេរ្តិ៍ជាសាធារណៈ។ ទោះបីជាយ៉ាងណា លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានមានប្រសាសន៍ថា "ការចាប់ខ្លួនពួកគេ គឺខុស ធ្វើតាមទំនើងចិត្ត"។

ខេមបូចាបានសង្កេតឃើញមានករណីចំនួន៩ពាក់ព័ន្ធនឹងការរំលោភសិទ្ធិបញ្ចេញមតិដោយសេរីរបស់អ្នកសារព័ត៌មាន អំឡុងត្រីមាសនេះ។ នៅក្នុងរបាយការណ៍នេះ យើងក៏បានចងក្រងព័ត៌មានថ្មីៗស្តីពីព័ត៌មានក្លែងក្លាយ ការឃ្លាំមើលតាមប្រព័ន្ធអនឡាញ និងគោលការណ៍ណែនាំស្តីពីការរាយការណ៍ ដែលគោរពតាមសមភាពយេនឌ័រ។

**ទាំងអស់គ្នាដើម្បីសេរីភាពសារព័ត៌មាន**

# ករណីដែលត្រូវបានរាយការណ៍នៅត្រីមាសនេះ

## ករណីប្រឆាំងអ្នកសារព័ត៌មាន ៖

១ រដ្ឋមន្ត្រីក្រសួងព័ត៌មានរិះគន់អភិបាលខេត្ត ៖ ការចាប់ខ្លួនអ្នកកាសែតគឺ "ខុស"

២ ពលរដ្ឋនៅខេត្តកំពត និងអ្នកសារព័ត៌មានត្រូវបានដោះលែងក្រោយពីត្រូវបានចាប់ខ្លួនពាក់ព័ន្ធជម្លោះដីធ្លី

៣ តុលាការសម្រេចផ្តន្ទាទោសអ្នកសារព័ត៌មាន៨នាក់ដាក់ពន្ធនាគារពាក់ព័ន្ធករណីជំរិតទារប្រាក់ពីម្ចាស់ដេប៉ូឈើ

៤ សាលាឧទ្ធរណ៍បើកសវនាការលើបទញុះញង់ប្រឆាំងអតីតអ្នកសារព័ត៌មានកាសែត ឌឹ ខេមបូឌា ដេលី

៥ អ្នកសារព័ត៌មានពីរនាក់ត្រូវបានចោទប្រកាន់ពីបទប៉ុនប៉ងគំរាមទារប្រាក់

៦ នគរបាលរាជធានីភ្នំពេញហាមអ្នកសារព័ត៌មានផ្សាយបន្តផ្ទាល់ពីសកម្មភាពអនុវត្តច្បាប់

៧ អ្នកជំនាញផ្នែកសារព័ត៌មានអំពាវនាវឲ្យមានការសហការលើកកម្ពស់សុវត្ថិភាពអ្នកសារព័ត៌មាន

# បច្ចុប្បន្នភាពផ្សេងៗ


I អង្គការសង្គមស៊ីវិលអំពាវនាវឲ្យអាជ្ញាធរកម្ពុជាបង្កើនការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាពចំពោះបទឧក្រិដ្ឋដែលប្រព្រឹត្តមកលើអ្នកសារព័ត៌មាន

II ប្រព័ន្ធផ្សព្វផ្សាយលើកឡើងថា ច្រកទ្វារអ៊ីនធឺណិតរបស់ប្រទេសកម្ពុជាធ្វើឲ្យអ្នកសារព័ត៌មានកាន់តែប្រយ័ត្នប្រយែងជាងមុន

III ក្រសួងព័ត៌មានបានរកឃើញព័ត៌មានក្លែងក្លាយជិត២.០០០ ករណីចាប់តាំងពីខែមករា

IV អ្នកជំនាញផ្នែកសារព័ត៌មានអំពាវនាវឲ្យមានកិច្ចសហការលើកកម្ពស់សុវត្ថិភាពអ្នកសារព័ត៌មាន ( យូណេស្កូ)

V គោលការណ៍ណែនាំស្តីពីការរាយការណ៍ដែលគោរពតាមសមភាពយេនឌ័រសម្រាប់ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា

VI កម្ពុជាចិនសហការគ្នាលើវិស័យព័ត៌មាន

VII កិច្ចសហប្រតិបត្តិការប្រឆាំងព័ត៌មានក្លែងក្លាយអាស៊ី-អឺរ៉ុបត្រូវបានជំរុញឱ្យមានការពង្រឹង

VIII បណ្តាញព័ត៌មានបោះពុម្ព អនឡាញនិងទូរទស្សន៍នៅក្នុងកម្ពុជាកើនជាង២.០០០ស្ថាប័ន

IX ការប្រមើលមើលពីសេរីភាពនិងឯករាជ្យភាពប្រព័ន្ធផ្សព្វផ្សាយ៖ រឿងរ៉ាវពីតំបន់អាស៊ីអាគ្នេយ៍

X ទិវាសិទ្ធិមនុស្ស៖ អ្នកសារព័ត៌មានចំនួន៤៥នាក់ត្រូវបានសម្លាប់នៅទូទាំងពិភពលោកក្នុងឆ្នាំ២០២១ និង៣៦៥នាក់កំពុងជាប់ពន្ធនាគារនៅឡើយ

XI និន្នាការពិភពលោកទាក់ទិនសេរីភាពនៃការបញ្ចេញមតិ និងការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

# សុវត្ថិភាព និងសន្តិសុខរបស់អ្នកសារព័ត៌មាន

បរិយាកាសដែលគ្មានគ្រោះថ្នាក់ដល់រាងកាយនិងផ្លូវចិត្ត គឺសំខាន់ណាស់សម្រាប់សេរីភាពសារព័ត៌មាន ។ ម្យ៉ាងវិញទៀត ប្រជាពលរដ្ឋត្រូវតែទទួលបានសេរីភាពនៃការបញ្ចេញមតិតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឬមធ្យោបាយណាមួយផ្សេងទៀតដោយគ្មានផលប៉ះពាល់ ។ នៅក្នុងត្រីមាសនេះ យើងបានសង្កេតឃើញករណីនៃការគំរាមកំហែងមកលើសេរីភាពជាមូលដ្ឋានទាំងនេះពីសំណាក់អាជ្ញាធរមូលដ្ឋាន និងតាមផ្លូវតុលាការ ។

តារាង ១ ៖ ប្រភេទនៃការយាយី

| ប្រភេទនៃការយាយី | ចំនួនករណីដែលត្រូវបានរាយការណ៍ | ចំនួនអ្នកសារព័ត៌មាន |
|---|---|---|
| វិធានការផ្លូវច្បាប់ | ១ | ២ |
| អំពើហិង្សា/ការគំរាមកំហែង | ២ | ២ |
| ការឃាត់ខ្លួនដើម្បីសាកសួរ | ១ | ២ |
| ការចាប់ដាក់ពន្ធនាគារ | ១ | ២ |
| សរុប | ៥ | ៨ |

# សេចក្តីសង្ខេបអំពីករណីនៃការយាយីលើអ្នកសារព័ត៌មាន

## ១. រដ្ឋមន្ត្រីក្រសួងព័ត៌មានរិះគន់អភិបាលខេត្ត៖ ការចាប់ខ្លួនអ្នកសារព័ត៌មាន គឺខុស (វីអូឌី)

ដោយប្រមាទចោលការជំរុញរបស់ថ្នាក់ដឹកនាំខេត្តក្នុងការឃ្លាំមើលដ៏តឹងតែងលើអ្នកសារព័ត៌មានរដ្ឋមន្ត្រីក្រសួងព័ត៌មានកាលពីពាក់កណ្តាលខែវិច្ឆិកាបានរិះគន់ការឃុំខ្លួនអ្នកកាសែតពីរនាក់តាមទំនើងចិត្ត និងទទូចឲ្យអាជ្ញាធរសហការកាន់តែជិតស្និទ្ធជាមួយអ្នកសារព័ត៌មាន។

ថ្ងៃងកាលពីថ្ងៃអង្គារក្នុងសិក្ខាសាលាស្តីពីគោលការណ៍ណែនាំអ្នកសារព័ត៌មាន លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានលើកឡើងពីករណីអ្នកកាសែតពីរនាក់ ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី៨ ខែវិច្ឆិកា ខណៈពួកគេកំពុងយកព័ត៌មានអំពីការតវ៉ាដីធ្លីនៅខេត្តកំពតហើយថាប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនិងមិនប្រកាន់បក្សពួកបានដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

លោក កាញារីទ្ធ បានមានប្រសាសន៍ថា "បើ [អ្នកកាសែត] ថតមុខសាលាខេត្ត ម៉េចមិនឲ្យគេថត?" ។

ចាប់ហ្នឹងគឺខុស គឺការបំពានហើយ! ចឹងរដ្ឋបាលយើងជួនកាលក៏បំពានចឹងដែរ។ យើងអត់យល់! ឬដូច អភិបាលខេត្តមួយបាននិយាយថា អ្នកកាសែតទៅណាត្រូវរាយការណ៍ ត្រូវជូនដំណឹងដល់អាជ្ញាធរកន្លែងហ្នឹង ដើម្បីឲ្យគេដឹងគេអី។ មិនមែនអីចឹងទេ"។ ប្រភព ៖ https://bit.ly/3KKpn4l

## ២. ពលរដ្ឋនៅខេត្តកំពតនិងអ្នកសារព័ត៌មានត្រូវបានដោះលែងក្រោយពីត្រូវបានចាប់ខ្លួនពាក់ព័ន្ធជម្លោះដីធ្លី (វីអូឌី)

អ្នកកាសែតពីរនាក់ដែលត្រូវបានចាប់ខ្លួនដោយសារចុះយកព័ត៌មានអំពីការតវ៉ាដីធ្លីមួយកន្លែងនៅខេត្តកំពត នោះត្រូវបានដោះលែងកាលពីថ្ងៃទី១១ខែវិច្ឆិកាបន្ទាប់ពីត្រូវបានឃុំខ្លួនកាលពីដើមសប្តាហ៍នោះខណៈពលរដ្ឋ បីនាក់ផ្សេងទៀតដែលជាផ្នែកនៃជម្លោះដីធ្លីនេះ ក៏ត្រូវបានដោះលែងពីការឃុំខ្លួនផងដែរ។

ប្រជាពលរដ្ឋ៤នាក់នៅស្រុកឈូកខេត្តកំពតត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី៧ វិច្ឆិកា ពីបទប្រើអំពើហិង្សាលើ ម្ចាស់អចលនទ្រព្យ។ អ្នកសារព័ត៌មានពីរនាក់មកពីបណ្តាញព័ត៌មាន Luos Seng News ត្រូវបានចាប់ខ្លួន កាលពីថ្ងៃទី៨ ខែវិច្ឆិកា នៅពេលដែលក្រុមអ្នកតវ៉ាទាមទារឲ្យដោះលែងអ្នកភូមិទាំង៤នាក់ ដែលរួមទាំងកុមារ អាយុ៤ឆ្នាំម្នាក់ផង។ កុមាររូបនេះបានជួបជុំគ្រួសារវិញនៅថ្ងៃទី១០ ខែវិច្ឆិកា។

បណ្តាញព័ត៌មាន Luos Seng News ក៏បានបញ្ជាក់ផងដែរថា អ្នកកាសែតរបស់ខ្លួនគឺលោក សាយ សុភា និងលោក អ៊ឹង ធឿន ត្រូវបានដោះលែង។ អ្នកកាសែតទាំងពីរត្រូវបានអនុញ្ញាតឲ្យធ្វើការសូមអភ័យទោស ជាសាធារណៈកាលពីព្រឹកថ្ងៃពុធ ប៉ុន្តែក្រោយមកបានបញ្ជូនពួកគេភ្លាមៗទៅកាន់តុលាការ ដើម្បីសាកសួរបន្ថែម ប្រភព ៖ https://bit.ly/33Pfn9v

## ៣. តុលាការសម្រេចផ្តន្ទាទោសអ្នកសារព័ត៌មាន៨នាក់ដាក់ពន្ធនាគារក្នុងសំណុំរឿងជំរិតទារប្រាក់ម្ចាស់ដេប៉ូឈើ (ខេមបូចា)

សាលាដំបូងខេត្តព្រះវិហារកាលពីថ្ងៃទី២១ ខែតុលា បានផ្តន្ទាទោសអ្នកសារព័ត៌មាន ៨នាក់ឲ្យជាប់ពន្ធនាគារ បន្ទាប់ពីកាត់ទោសពួកគេពីបទជំរិតទារប្រាក់ពីម្ចាស់ដេប៉ូឈើមួយកន្លែងកាលពីខែមិថុនា។

អ្នកសារព័ត៌មានទាំងនេះត្រូវបានឃាត់ខ្លួនភ្លាមៗបន្ទាប់ពីម្ចាស់ដេប៉ូឈើបានរាយការណ៍ថាក្រុមអ្នកសារព័ត៌មាន បានថតរូបដោយគ្មានការអនុញ្ញាតនៅក្នុងតំបន់ឯកជនក្នុងដេប៉ូឈើនោះ។

លោក គឹម សំឡេង ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តបានប្រាប់ខេមបូចាថា អ្នកសារព័ត៌មានចំនួនប្រាំពីរ រូបក្នុងចំណោមពួកគេត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ ប៉ុន្តែអនុវត្តទោសក្នុងពន្ធនាគារ តែ៤ខែនិង២០ថ្ងៃប៉ុណ្ណោះ ហើយទោសដែលនៅសល់គឺត្រូវបានព្យួរជម្ងតា។

*អ្នកសារព័ត៌មានទី៨ ត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្នរួចហើយ។ ក្រុមអ្នកសារព័ត៌មានទាំងនេះត្រូវបានឃាត់ខ្លួននៅថ្ងៃទី៤ ខែមិថុនា ហើយអ្នកសារព័ត៌មានទាំង៧នាក់ ដែលអនុវត្តទោសយូរជាងនឹងត្រូវដោះលែងនៅថ្ងៃទី២២ ខែតុលា។*

*លោក ឌួន ផានិត មេធាវីតំណាងឲ្យអ្នកសារព័ត៌មានបួននាក់ក្នុងចំណោមអ្នកសារព័ត៌មានទាំងប្រាំបីនាក់នេះ បាននិយាយថា ទោះបីជាតុលាការផ្ដន្ទាទោសកូនក្ដីរបស់លោកក្នុងកម្រិតអប្បបរមាក៏ដោយ ក៏កូនក្ដីរបស់លោកនៅតែប្រឈមនឹងភាពអយុត្តិធម៌ ដោយសារតែគ្មានភស្តុតាងគ្រប់គ្រាន់ ដើម្បីផ្ដន្ទាទោសពួកគេពីបទគំរាមទារប្រាក់នោះទេ។*

*លោកផានិតក៏បានជំរុញឲ្យអ្នកសារព័ត៌មានប្រកាន់ខ្ជាប់នូវក្រមសីលធម៌និងគោរពច្បាប់ស្ដីពីរបបសារព័ត៌មាន ដើម្បីបញ្ចៀសពីការប្រព្រឹត្តខុសជាយថាហេតុណាមួយ។ ប្រភព ៖* https://bit.ly/3fUypxl

## ៤. សាលាឧទ្ធរណ៍បើកសវនាការលើបទញុះញង់ប្រឆាំងអតីតអ្នកសារព័ត៌មាន កាសែត ឌឹ ខេមបូឌា ដេលី

*លោក* Zsombor Peter *និងលោក អួន ភាព អតីតអ្នកសារព័ត៌មានកាសែត ឌឹ ខេមបូឌា ដេលី* (The Cambodia Daily) *បានអំពាវនាវឲ្យទម្លាក់នូវអ្វីដែលអ្នកទាំងពីរចាត់ទុកថាជា "ការចោទប្រកាន់ក្លែងក្លាយ" ពីបទញុះញង់ជុំវិញការធ្វើសេចក្ដីរាយការណ៍ព័ត៌មានពីការបោះឆ្នោតឃុំសង្កាត់កាលពីឆ្នាំ២០១៧។*

*ការអំពាវនាវរបស់អ្នកសារព័ត៌មានទាំងពីរធ្វើឡើង បន្ទាប់ពីសាលាឧទ្ធរណ៍ខេត្តត្បូងឃ្មុំបានបើកសវនាការជំនុំជម្រះលើសំណុំរឿងរបស់ពួកគាត់កាលពីថ្ងៃទី១៦ ខែធ្នូ។ សវនាការនេះបានធ្វើឡើង ក្រោយពីតំណាងអយ្យការអមសាលាដំបូងខេត្តរតនគិរីប្ដឹងឧទ្ធរណ៍នឹងសេចក្ដីសម្រេចរបស់ចៅក្រមសាលាដំបូងខេត្តនេះដែលបានទម្លាក់បទចោទលើអ្នកសារព័ត៌មានទាំងពីរ។*

*កាលពីថ្ងៃទី៤ ខែមករា សាលាឧទ្ធរណ៍បានតម្កល់សេចក្ដីសម្រេចរបស់តុលាការជាន់ទាបដែលបានទម្លាក់ចោលបទចោទញុះញង់លើអ្នកសារព័ត៌មានទាំងពីរ។*

*លោកទុំ សោភ័ណ អ្នកនាំពាក្យសាលាឧទ្ធរណ៍ខេត្តត្បូងឃ្មុំមានប្រសាសន៍ថា សំណុំរឿងរបស់អ្នកសារព័ត៌មានទាំងពីរនឹងបញ្ចប់នៅទីនេះ លែកលែងតែអគ្គព្រះរាជអាជ្ញាប្ដឹងឧទ្ធរណ៍នឹងសេចក្ដីសម្រេចនេះបន្តទៀត។ ប្រភព ៖* https://bit.ly/3nXmLGL

## ៥. អ្នកសារព័ត៌មានពីរនាក់ត្រូវបានចោទប្រកាន់ពីបទប៉ុនប៉ងគំរាមទារប្រាក់ ( ខ្មែរ ថាមស៍ )

*សាលាដំបូងរាជធានីភ្នំពេញកាលពីថ្ងៃទី២៣ ខែធ្នូ បានសម្រេចចោទប្រកាន់និងឃុំខ្លួនអ្នកសារព័ត៌មាន ២នាក់ពីបទប៉ុនប៉ងជំរិតទារប្រាក់៦០០ដុល្លារ ពីម្ចាស់ហាងកាហ្វេមួយកន្លែង ដែលផ្តល់សេវាល្បែងស៊ីសង ខុសច្បាប់តាមអនឡាញជាថ្នូរនឹងការបិទព័ត៌មាន។*

*ចៅក្រមស៊ើបសួរ លោក សេង លាង បានបញ្ជាក់អត្តសញ្ញាណជនជាប់ចោទទាំង២នាក់ គឺឈ្មោះ អ៊ុន ចន្ថា អាយុ៣៩ឆ្នាំ ជាចាងហ្វាងបណ្តាញព័ត៌មានរស្មីក្រុងតាខ្មៅ និងឈ្មោះ ឆោម ដានី អាយុ៣២ឆ្នាំ ជាចាងហ្វាង បណ្តាញព័ត៌មានកងមាស។*

*លោកចៅក្រម សេង លាង បាននិយាយថា អ្នកទាំងពីរត្រូវបានចោទប្រកាន់ពីបទ "គំរាមកំហែងហែកកេរ្តិ៍ តាមមាត្រា៣៧២ និង៣៧៣នៃក្រមព្រហ្មទណ្ឌ។ ប្រសិនបើត្រូវបានផ្តន្ទាទោស ពួកគេប្រឈមនឹងការជាប់ ពន្ធនាគារពី២ទៅ៥ឆ្នាំក្នុងម្នាក់ៗ។ ប្រភព ៖* https://bit.ly/3KPLM0r

## ៦. នគរបាលរាជធានីភ្នំពេញហាមអ្នកសារព័ត៌មានថតផ្សាយផ្ទាល់ពីសកម្មភាពអនុវត្តច្បាប់

*នគរបាលរាជធានីភ្នំពេញ បានហាមអ្នកសារព័ត៌មានមិនឲ្យថតផ្សាយផ្ទាល់ពេលអាជ្ញាធរអនុវត្តច្បាប់តាមដងផ្លូវ។*

*លោកឧត្តមសេនីយ៍ឯក ស ថេត ស្នងការនគរបាលរាជធានីភ្នំពេញបានណែនាំដល់គ្រប់អង្គភាពក្រោមឱវាទនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញហាមដាច់ខាតមិនឲ្យអ្នកសារព័ត៌មានថតផ្សាយផ្ទាល់សកម្មភាព អនុវត្តច្បាប់។*

*ការណែនាំនេះត្រូវបានធ្វើឡើងកាលពីថ្ងៃទី៦ ខែតុលា អំឡុងពេលកិច្ចប្រជុំតាមអនឡាញ ដើម្បីពិនិត្យមើល ការងាររបស់នគរបាលដែលបានធ្វើកាលពីខែកន្លងមកនិងផែនការសម្រាប់ខែនេះ។*

*លោកឧត្តមសេនីយ៍ឯក ស ថេត ក៏បានបញ្ជាក់ផងដែរថា ប្រសិនបើអ្នកសារព័ត៌មានមិនគោរពតាមការណែនាំ របស់អាជ្ញាធរទេ ត្រូវចាត់វិធានការចំពោះពួកគេ ព្រោះការផ្សាយរបស់ពួកគេអាចនាំឲ្យជនសង្ស័យរត់គេចពី ការចាប់ខ្លួន។ ប្រភព ៖* https://bit.ly/3rSCGXR

# ការធ្វើសេចក្ដីរាយការណ៍ក្នុងស្ថានភាពប្រឈម៖ បច្ចុប្បន្នភាពអំពីស្ថានភាពប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននៅកម្ពុជា

*ភាពភ័យខ្លាចពីបញ្ហាផ្លូវច្បាប់នៅតែកើតមានជាប្រចាំនៅក្នុងពេលបំពេញការងារក្នុងចំណោមបញ្ហាប្រឈមជាច្រើនផ្សេងទៀតដែលអ្នកសារព័ត៌មានកម្ពុជាកំពុងជួបប្រទះ ។ អ្នកសារព័ត៌មានតែងតែមានអារម្មណ៍ថាខ្លួនរងការបំភិតបំភ័យ ឬការគំរាមកំហែងដោយសារវិធានការរបស់រដ្ឋាភិបាល មិនថាជាសកម្មភាពរាំងអ្នកសារព័ត៌មានមិនឲ្យថតរូប ឬការចាត់វិធានការផ្លូវច្បាប់លើពួកគេដោយគ្រាន់តែបំពេញការងាររបស់ខ្លួននោះទេ។*

## កំនត់ត្រាការយាយី (ខែមករា ដល់ ខែធ្នូ ឆ្នាំ២០២១)



កំនត់ត្រាការយាយីសរុប

**៥១**

លើអ្នកសារព័ត៌មាន៩៣នាក់ (ស្ត្រី៥នាក់)



៣២នាក់ក្នុងចំណោមពួកគេត្រូវបានចាប់ខ្លួន



១០នាក់ប្រឈមនឹងវិធានការណ៍ច្បាប់

១៨នាក់រងអំពើហិង្សា និងការយាយី






អាជ្ញាប័ណ្ណរបស់ស្ថាប័នព័ត៌មានចំនួន៧ ត្រូវបានលុបចោល

## I. អង្គការសង្គមស៊ីវិលអំពាវនាវឲ្យអាជ្ញាធរកម្ពុជាបង្កើនការប្រយុទ្ធប្រឆាំង នឹងនិទ្ទណ្ឌភាពចំពោះបទឧក្រិដ្ឋដែលប្រព្រឹត្តលើអ្នកសារព័ត៌មាន

ខេមបូចា និងអង្គការសង្គមស៊ីវិលចំនួន៨ បានចេញសេចក្តីថ្លែងការណ៍កាលពីថ្ងៃទី២ ខែវិច្ឆិកា៖ នៅក្នុងទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពចំពោះបទឧក្រិដ្ឋប្រឆាំងអ្នកសារព័ត៌មានអង្គការសង្គមស៊ីវិលដែលមានរាយនាមដូចខាងក្រោមបង្ហាញការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការ ដែលរដ្ឋាភិបាលកម្ពុជាបរាជ័យក្នុងការនាំយកជនដៃដល់ដែលប្រព្រឹត្តបទឧក្រិដ្ឋលើអ្នកសារព័ត៌មាននៅកម្ពុជាមកផ្តន្ទាទោស។

យើងទទូចឲ្យអាជ្ញាធរចាត់វិធានការជាបន្ទាន់ ដើម្បីធានាឲ្យមានការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ឯករាជ្យភាព និងតម្លាភាពទៅលើគ្រប់ករណីនៃបទឧក្រិដ្ឋទាំងអស់ ហើយថាជនរងគ្រោះត្រូវតែទទួលបានយុត្តិធម៌។

ចាប់តាំងពីឆ្នាំ១៩៩២មក យ៉ាងហោចណាស់មានអ្នកសារព័ត៌មាន១៧នាក់ត្រូវបានគេសម្លាប់និងស្លាប់នៅក្នុងប្រទេសកម្ពុជា។ ស្ទើរតែគ្រប់ករណីទាំងអស់នេះ ជនរងគ្រោះបានក្លាយជាគោលដៅដោយសារតែការងាររបស់ពួកគេ។ ជនរងគ្រោះ១២នាក់ក្នុងចំណោមអ្នកសារព័ត៌មាន១៧នាក់ដែលត្រូវបានគេសម្លាប់ បានធ្វើសេចក្តីរាយការណ៍ព័ត៌មានអំពីបញ្ហារសើប ហើយទទួលមរណភាព។ លើសពីនេះទៅទៀត មាន១២ករណីដែលជនដៃដល់មិនទាន់ត្រូវបាននាំយកមកផ្តន្ទាទោសនៅឡើយ។

ជាងនេះទៅទៀត ការធ្វើទុក្ខបុកម្នេញនិងអំពើឧក្រិដ្ឋលើអ្នកសារព័ត៌មានហាក់មានការកើនឡើងគួរឲ្យព្រួយបារម្ភ។

យោងតាមសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) បានឲ្យដឹងថា អ្នកសារព័ត៌មានចំនួន៨១នាក់បានក្លាយជាគោលដៅក្នុងរយៈពេលត្រឹមតែ១០ខែចុងក្រោយប៉ុណ្ណោះ (ខែមករាដល់ខែតុលា ឆ្នាំ២០២១)។

ក្នុងចំណោមអ្នកកាសែតទាំងនោះ ៣១នាក់ត្រូវបានចាប់ខ្លួន (ស្រី៤នាក់) ១៨នាក់ទទួលរងអំពើហិង្សា ១៦នាក់រងការគំរាមកំហែង ៨នាក់ប្រឈមមុខនឹងការឃាយីតាមផ្លូវតុលាការ ៥នាក់ត្រូវបានឃាត់ខ្លួនដើម្បីសាកសួរ និងអ្នកកាសែតស្រីម្នាក់ទទួលរងការបៀតបៀនផ្លូវភេទ។ ប្រភព ៖ https://bit.ly/3KKdrjm

## II. ប្រព័ន្ធផ្សព្វផ្សាយលើកឡើងថា ច្រកទ្វារអ៊ីនធើណិតរបស់ប្រទេសកម្ពុជាធ្វើឲ្យអ្នកសារព័ត៌មានកាន់តែប្រយ័ត្នប្រយែងជាងមុន (Voice of America)

*លោក យុត សុគន្ធ ជាអ្នកសារព័ត៌មានប្រចាំកម្មវិធីវិទ្យុមួយនិយាយថា លោកធ្វើសេចក្តីការណ៍តិចជាងមុននៅឆ្នាំនេះ។ មូលហេតុ៖ បារម្ភអំពីច្រកទ្វារអ៊ីនធើណិតជាតិរបស់កម្ពុជា ដែលលោកនិងអ្នកខ្លះនិយាយថាអនុញ្ញាតឲ្យរដ្ឋាភិបាលឃ្លាំមើលរាល់សកម្មភាពតាមអនឡាញ។*

*ក្រុមហ៊ុនផ្តល់សេវាអ៊ីនធើណិតនៅក្នុងប្រទេសកម្ពុជាមានពេលរហូតដល់ខែកុម្ភៈ ឆ្នាំ២០២២ ដើម្បីបង្វែរទិសចរាចរណ៍របស់ខ្លួនទាំងអស់តាមរយៈស្ថាប័ននិយ័តកម្ម ឬច្រកទ្វារអ៊ីនធើណិតជាតិដែលគេស្គាល់ថា NIG ។*

*ប៉ុន្តែចាប់តាំងពីរដ្ឋាភិបាលរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចេញបទបញ្ជា ដែលនៅកម្ពុជាគេស្គាល់ថាជាអនុក្រឹត្យកាលពីដើមឆ្នាំនេះមក លោកសុគន្ធបាននិយាយថា លោកចាប់ផ្តើមអនុវត្ត"វិធីសាស្ត្រដ៏ប្រុងប្រយ័ត្នជាងមុន" ចំពោះការធ្វើសេចក្តីរាយការណ៍និងការបញ្ចេញមតិរបស់លោកតាមអនឡាញ។*

*លោក សុគន្ធ មិនមែនជាមនុស្សតែម្នាក់គត់ដែលធ្វើបែបនេះនោះទេ។ អ្នកសារព័ត៌មាននិងអង្គការសិទ្ធិមនុស្សផ្សេងទៀតដែលផ្តល់បទសម្ភាសជាមួយ VOA និយាយថា បទបញ្ញត្តិដែលអនុញ្ញាតឲ្យមានការដាក់ទណ្ឌកម្ម"យោងទៅតាមច្បាប់ពាក់ព័ន្ធ" បានធ្វើឲ្យមានការភ័យខ្លាចកាន់តែខ្លាំងឡើងអំពីការចាប់ខ្លួននៅក្នុងចំណោមប្រព័ន្ធផ្សព្វ ផ្សាយ អ្នករិះគន់និងប្រជាពលរដ្ឋសាមញ្ញ។*

*នៅក្នុងប្រទេសដែលសេរីភាពប្រព័ន្ធផ្សព្វផ្សាយត្រូវបានរឹតត្បិត អំណាចដ៏ទូលំទូលាយ ដែលមានចែងក្នុង NIG រួមទាំងអំណាចក្នុងការឃ្លាំមើលសកម្មភាពនិងការបិទ ឬផ្តាច់ប្រព័ន្ធអ៊ីនធើណិតត្រូវបានមជ្ឈដ្ឋានជាច្រើនចាត់ទុកថា ជាឧបករណ៍មួយទៀត ដើម្បីបំបិទសំឡេងនិងបង្កើនការភ័យខ្លាច។ ប្រភព ៖* https://bit.ly/3C4RS8j;

## III. ក្រសួងព័ត៌មានរកឃើញព័ត៌មានក្លែងក្លាយជិត២.០០០ ករណីចាប់តាំងពីខែមករា

*គណៈកម្មការតាមដានការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយនៃក្រសួងព័ត៌មានបានស្រង់ប្រភពព័ត៌មានក្លែងក្លាយសរុបចំនួន១.៩៣៨ករណីក្នុងឆ្នាំ២០២១ ដែលសារទាំងនោះត្រូវបានចោទថា មានបំណងញុះញង់ឲ្យមានបទឧក្រិដ្ឋបង្កភាពវឹកវរក្នុងសង្គមឬប្រមាថដល់ថ្នាក់ដឹកនាំប្រទេស។ ការណ៍នេះបង្ហាញពីការកើនឡើងបន្តិចនៃសកម្មភាពបើធៀបនឹងឆ្នាំមុន។*

*យោងតាមរបាយការណ៍របស់គណៈកម្មការនេះដែលចេញផ្សាយកាលពីថ្ងៃទី១៧ ខែធ្នូ បានឲ្យដឹងថា ក្នុងចំណោម១.៩៣៨ករណី មានព័ត៌មានក្លែងក្លាយចំនួន ១.០២៣ ករណី ដែលមានចេតនាញុះញង់ឲ្យមានការ*

*រិះគន់រដ្ឋាភិបាលតាមរយៈព័ត៌មានមិនពិត។៨០៩ករណីគឺជាការប្រមាថព្រះមហាក្សត្រនិងថ្នាក់ដឹកនាំប្រទេស ចំណែក១០៦ ករណីនៃព័ត៌មានក្លែងក្លាយទាំងនេះទំនងជាអាចបង្កឲ្យមានភាពរឹករវក្នុងសង្គម។*

*លោក មាស សោភ័ណ្ឌ អ្នកនាំពាក្យក្រសួងព័ត៌មានបានប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី១៩ ខែធ្នូថា ភាគច្រើននៃព័ត៌មានក្លែងក្លាយត្រូវបានបង្ហោះតាមគណនីបណ្តាញសង្គមសរុបចំនួន៣៨៣ ដូចជា* Facebook TikTok *និង* Youtube *ឬតាមរយៈគេហទំព័រ។*

*គណៈកម្មការនេះក៏បានរកឃើញផងដែរថា ស្ថាប័នផ្សព្វផ្សាយព័ត៌មានចំនួន១១ ដែលបានចុះបញ្ជីជាមួយក្រសួងព័ត៌មានបានចុះផ្សាយអត្ថបទចំនួន៩៩ ដែលមានខ្លឹមសារបំផ្លើស ឬគ្មានការផ្ទៀងផ្ទាត់ព័ត៌មាន។ ករណីទាំង៩៩នេះ ត្រូវបានបញ្ជូនបន្តទៅឲ្យក្រុមការងារអន្តរក្រសួងដើម្បីចាត់ការបន្ត។*

*គណៈកម្មការនេះក៏បានស្នើសុំកិច្ចសហប្រតិបត្តិការពីដៃគូផ្សេងទៀតជាពិសេសក្រុមហ៊ុនបច្ចេកវិទ្យា ដែលដំណើរការប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីកំណត់អត្តសញ្ញាណជនសង្ស័យទាំងអស់ ដែលបានផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ។ ប្រភព ៖* https://bit.ly/3AzrMKH

## IV. អ្នកជំនាញផ្នែកសារព័ត៌មានអំពាវនាវឲ្យមានកិច្ចសហការលើកកម្ពស់សុវត្ថិភាពអ្នកសារព័ត៌មាន (យូណេស្កូ)

*នៅក្នុងសិក្ខាសាលាកាលពីថ្ងៃទី១៦ ខែវិច្ឆិកា ដោយមានអ្នកចូលរួមជាង២០០នាក់ មកពីសហគមន៍ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននិងរដ្ឋាភិបាល អង្គការយូណេស្កូបានសង្កត់ធ្ងន់ពីសារៈសំខាន់ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការដើម្បីបង្កើតយន្តការថ្នាក់ជាតិ និងការអនុវត្តគំនិតផ្តួចផ្តើមរួមគ្នា ដើម្បីធានាឲ្យមានការការពារអ្នកសារព័ត៌មាន និងលើកកម្ពស់សេរីភាពនៃការបញ្ចេញមតិនៅកម្ពុជា។*

*អំឡុងពេលថ្លែងសុន្ទរកថាបើកកម្មវិធី លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានហៅជំនួបនេះថាជាជំនួប "ប្រវត្តិសាស្ត្រ" ដោយសារថា នេះគឺជាលើកទីមួយហើយដែល "អ្នកសារព័ត៌មាន ក្រសួងព័ត៌មាន ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃបានមកជួបជុំគ្នា ដើម្បីពិភាក្សារកមធ្យោបាយធ្វើការរួមគ្នា ដើម្បីផលប្រយោជន៍លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា"។*

*សិក្ខាសាលាដែលរៀបចំដោយក្រសួងព័ត៌មាន និងមានការគាំទ្រពីអង្គការយូណេស្កូនេះ បា នផ្តល់ឱកាសពិសេសមួយសម្រាប់សហគមន៍ប្រព័ន្ធផ្សព្វផ្សាយនិងអាជ្ញាធរ ដើម្បីពិភាក្សាអំពីបញ្ហាបន្ទាន់បំផុត ដែលអ្នកសារព័ត៌មានកំពុងជួបប្រទះនៅក្នុងប្រទេសកម្ពុជា។*

តំណាងមកពីក្រសួងព័ត៌មាន ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃបានពន្យល់អំពីច្បាប់ជាតិទាក់ទងនឹងបណ្តាញផ្សព្វផ្សាយព័ត៌មាននិងការអនុវត្តរបស់ខ្លួន ហើយពួកគេបានស្តាប់បញ្ហាប្រឈមនិងកង្វល់ ដែលលើកឡើងដោយអ្នកសារព័ត៌មានដែលមានវត្តមាននៅក្នុងព្រឹត្តិការណ៍នេះ។

កិច្ចពិភាក្សានៅក្នុងសិក្ខាសាលានេះ បានចាប់ផ្តើមជាមួយនឹងការធ្វើបទបង្ហាញអំពីបញ្ហាប្រឈម ដែលអ្នកសារព័ត៌មានកម្ពុជាកំពុងជួបប្រទះនៅពេលបំពេញការងាររបស់ពួកគេ។

លោក ណុប វី នាយកប្រតិបត្តិនៃសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA) បានធ្វើបទបង្ហាញពីលទ្ធផលនៃរបាយការណ៍ឃ្លាំមើលរបស់សមាគមនេះអំពីការវាយប្រហារ និងការគំរាមកំហែង ដែលអ្នកសារព័ត៌មានជួបប្រទះក្នុងប្រទេសកម្ពុជា ហើយបានអំពាវនាវឲ្យអាជ្ញាធរពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសហគមន៍ប្រព័ន្ធផ្សព្វផ្សាយ ដើម្បីធានាបាននូវបរិយាកាសសុវត្ថិភាពសម្រាប់បុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ។
ប្រភព ៖ https://bit.ly/3rK1t0k

## V. គោលការណ៍ណែនាំស្តីពីការរាយការណ៍ដែលគោរពតាមសមភាពយេនឌ័រសម្រាប់ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា

ខេមបូចាលើកទឹកចិត្តឲ្យអ្នកសារព័ត៌មាន និងអ្នកជំនាញប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាអនុវត្តតាមគោលការណ៍ណែនាំស្តីពីការរាយការណ៍ដែលគោរពតាមសមភាពយេនឌ័រ ដែលត្រូវបានបង្កើតឡើងដោយដៃគូនៃកម្មវិធីបណ្តុះបណ្តាលអន្តរជាតិស្តីពីការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយក្នុងក្របខ័ណ្ឌប្រជាធិបតេយ្យ (ITPMedia) ក្នុងការអនុវត្តការងាររបស់ពួកគេ។

គោលការណ៍ណែនាំនេះត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួន ដើម្បីពិពណ៌នាខ្លឹមសារព័ត៌មាននៅកម្ពុជាក្នុងលក្ខណៈលើកកម្ពស់សមភាពយេនឌ័រ និងឆ្លើយតបតាមតម្រូវការយេនឌ័រឲ្យកាន់តែប្រសើរឡើង។ ដូច្នេះគោលការណ៍ណែនាំនេះនឹងរួមចំណែកដល់ការរាយការណ៍ប្រកបដោយបរិយាបន្ននិងសមភាព ដោយបង្ហាញពីបទពិសោធន៍និងតម្រូវការរបស់មនុស្សគ្រប់រូបឲ្យបានស្មើគ្នាទាំងស្ត្រី ក្មេងស្រី ក្មេងប្រុស បុរស និងអ្នកផ្សេងទៀតដែលស្ថិតក្នុងក្រុមដែលមិនត្រូវបានយកចិត្តទុកដាក់។

ជាមួយនឹងគោលការណ៍ណែនាំស្តីពីការរាយការណ៍ដែលគោរពតាមសមភាពយេនឌ័រនេះ យើងរំពឹងថា នឹងមានការពិពណ៌នាអំពីស្ត្រី ដែលត្រូវបានផ្តល់អំណាចបែបវិជ្ជមានកាន់តែច្រើនឡើងនៅលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានគ្រប់ប្រភេទនៅប្រទេសកម្ពុជា។ ដូច្នេះ គោលការណ៍ណែនាំនេះ ក៏នឹងអាចរួមចំណែកកាត់បន្ថយវិសមភាព ការបន្ទុចបង្អាក់និងការបន្ទាបបន្ថោកស្ត្រីនៅក្នុងសង្គមកម្ពុជាផងដែរ។
ប្រភព ៖ https://bit.ly/3nZ1xIG

## VI. កម្ពុជានិងចិនសហការគ្នាលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន (ខ្មែរថាមស៍)

*មេដឹកនាំប្រព័ន្ធផ្សព្វផ្សាយជាង៣០នាក់មកពីប្រទេសកម្ពុជា និងចិនបានមកចូលរួមក្នុងសិក្ខាសាលាកម្រិតខ្ពស់រយៈពេលបីថ្ងៃដែលធ្វើឡើងក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងដែលបានចាប់ផ្តើមកាលពីថ្ងៃទី២០ខែតុលាហើយដែលត្រូវបានរៀបចំឡើងដោយសមាគមអ្នកកាសែតកម្ពុជា-ចិន(CJC)ដោយសហការជាមួយមូលនិធិចិន ដើម្បីសន្តិភាពនិងការអភិវឌ្ឍន៍។*

*លោក សយ សុភាព ប្រធាន CJC បាននិយាយថា ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង CJC បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ក្រៅពីការផ្សារភ្ជាប់ទំនាក់ទំនងប្រព័ន្ធផ្សព្វផ្សាយរវាងប្រទេសទាំងពីរ ដើម្បីឲ្យមានការយល់ដឹងកាន់តែប្រសើរជាងមុនអំពីប្រជាជាតិទាំងពីរ។*

*លោក Wang Hua អគ្គលេខាធិការរងនៃមូលនិធិចិន ដើម្បីសន្តិភាពនិងការអភិវឌ្ឍន៍បានលើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយកម្ពុជានិងចិន ឲ្យពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀត ដើម្បីជំរុញការយល់ដឹងកាន់តែស៊ីជម្រៅអំពីគ្នាទៅវិញទៅមកនិងក្នុងតំបន់ផងដែរ។*

*លោក Wang មានប្រសាសន៍ថា “ការយល់ដឹងនិងការជឿទុកចិត្តគ្នា គឺជាកត្តាចម្បងក្នុងការកសាងសន្តិភាពរវាងកម្ពុជាចិននិងតំបន់ ហើយប្រព័ន្ធផ្សព្វផ្សាយមានតួនាទីសំខាន់”។ ប្រភព ៖* https://bit.ly/3H52QNo

## VII. កិច្ចសហប្រតិបត្តិការរវាងអ្នកសារព័ត៌មានប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ អាស៊ី-អឺរ៉ុប ត្រូវបានជំរុញឱ្យមានការពង្រឹង (ខ្មែរថាមស៍)

*វេទិកាតុមូលនិពន្ធនាយកសារព័ត៌មានអាស៊ី-អឺរ៉ុបលើកទី១០ (ASEFERT10) បានបិទបញ្ចប់និងចាត់ទុកកិច្ចសហប្រតិបត្តិការដ៏មោះមុតថាសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយរវាងទ្វីបទាំងពីរ គឺអាស៊ី និងអឺរ៉ុប។*

*កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងបន្ទាប់ពីមានការពិភាក្សាជាច្រើនរវាងអ្នកប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយនៃទ្វីបទាំងពីរ អំឡុងវេទិកាតុមូលរយៈពេលពីរថ្ងៃដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះក្នុងទម្រង់កូនកាត់។*

*ក្រោមប្រធានបទ "ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងអ្នកសារព័ត៌មានក្នុងការប្រយុទ្ធប្រឆាំព័ត៌មានក្លែងក្លាយ" ASEFERT10 គឺជាព្រឹត្តិការណ៍មួយក្នុងចំណោមព្រឹត្តិការណ៍សំខាន់នៃជំនួបកំពូលអាស៊ី-អឺរ៉ុបលើកទី១៣(ASEM13) ដែលត្រូវបានរៀបចំឡើងដោយប្រទេសកម្ពុជាកាលពីថ្ងៃទី២៥-២៦ ខែវិច្ឆិកា។ ASEFERT10 រៀបចំសម័យប្រជុំពេញអង្គចំនួនពីរលើក និងវេទិកាសាធារណៈមួយលើក។*

*យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់ក្រសួងព័ត៌មានបានឲ្យដឹងថា អំឡុងសម័យប្រជុំពេញអង្គលើកទី១ និពន្ធនាយកមកពីទីបទាំងពីរបានចែករំលែកព័ត៌មាន បទពិសោធន៍និងស្ថានភាពបច្ចុប្បន្ននៃការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយនៅក្នុងប្រទេសរៀងៗខ្លួន។*

*ពួកគេក៏បានពិភាក្សានិងចែករំលែកបទពិសោធន៍ដែលបានឆ្លងកាត់និងការអនុវត្តប្រសើរបំផុតនៅក្នុងប្រទេសរៀងៗខ្លួនក្នុងការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ ហើយបានលើកឡើងពីតួនាទីសំខាន់ៗ និងការទទួលខុសត្រូវរបស់អ្នកសារព័ត៌មានក្នុងការផ្សព្វផ្សាយការពិតនិងព័ត៌មានដែលអាចជឿទុកចិត្តបានដល់សាធារណជន លើកទឹកចិត្តសាធារណជនឲ្យទទួលយកការអប់រំតាមរយៈអក្ខរភាពប្រព័ន្ធផ្សព្វផ្សាយនិងបណ្ដុះបណ្ដាលអ្នកសារព័ត៌មានប្រជាពលរដ្ឋឲ្យយល់ពីក្រមសីលធម៌និងវិជ្ជាជីវៈ។*

*ប្រភព ៖* [https://bit.ly/3G1ErXO](https://bit.ly/3G1ErXO)

## VIII. បណ្ដាញព័ត៌មានបោះពុម្ព ព័ត៌មានអនឡាញនិងទូរទស្សន៍នៅកម្ពុជាកើនដល់ជាង២.០០០ស្ថាប័ន

*ក្រសួងព័ត៌មានបានធ្វើបច្ចុប្បន្នភាពចំនួនស្ថាប័នព័ត៌មាន ដែលបានចុះបញ្ជីដោយកត់សម្គាល់ថា ស្ថាប័នព័ត៌មានជាង២.០០០ បានដំណើរការស្របតាមច្បាប់តម្រូវ គិតត្រឹមដំណាច់ឆ្នាំ២០២១។*

*ទោះបីជាយ៉ាងណា ក្រសួងក៏បានលុបចោលអាជ្ញាប័ណ្ណរបស់ស្ថាប័នព័ត៌មានចំនួន១៥ ផងដែរ ដោយសារតែបានរំលោភច្បាប់ឬក៏ម្ចាស់ស្ថាប័នទាំងនោះមិនបន្តសុពលភាព។*

*លោក ផុស សុវណ្ណ អគ្គនាយកនៃអគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍របស់ក្រសួងព័ត៌មានបានមានប្រសាសន៍ថា អាជ្ញាប័ណ្ណភាគច្រើនដែលត្រូវបានលុបចោលគឺ ជាអាជ្ញាប័ណ្ណរបស់បណ្ដាញផ្សព្វផ្សាយព័ត៌មានតាមអនឡាញ។*

*លោក សុវណ្ណ បានប្រាប់ភ្នំពេញប៉ុស្ដិ៍នៅថ្ងៃទី៥ ខែមករាថា មានស្ថាប័នព័ត៌មានសរុបចំនួន២.០១៧ បានចុះបញ្ជីក្នុងនោះ ៧០៦ស្ថាប័នគឺជាគេហទំព័រ ៨១គឺជាស្ថាប័នព័ត៌មានវីដេអូ ហើយ២៣ស្ថាប័នក្នុងចំណោមនោះកាន់កាប់ដោយបរទេស។*

*លោកមានប្រសាសន៍ថា"យើងបានដកហូតអាជ្ញាប័ណ្ណមួយចំនួនដោយសារតែពួកគេបំពានច្បាប់ៗ មួយចំនួនទៀតទើបផុតកំណត់ ហើយមួយចំនួនទៀតត្រូវបានលុបចោលតាមសំណើរបស់ម្ចាស់ ព្រោះពួកគេឈប់ធ្វើអាជីវកម្មហើយឈប់ផ្សព្វផ្សាយ ឬបោះពុម្ពផ្សាយបន្តទៀតហើយ"។*

*លោកក៏បានកត់សម្គាល់ផងដែរថា ប្រទេសកម្ពុជាមានសមាគមសារព័ត៌មានសរុបចំនួន៥០ ទស្សនាវដ្ដី១៩៣ ព្រឹត្តិបត្រព័ត៌មាន២២ ពេងពុម្ព១១៤កន្លែង គ្រឹះស្ថានបោះពុម្ពសៀវភៅចំនួន២២ និងទីភ្នាក់ងារសារព័ត៌មានបរទេសចំនួន២៦ ដែលមានការិយាល័យតំណាងក្នុងប្រទេសកម្ពុជា។ ប្រភព ៖* [https://bit.ly/3HORkpz;](https://bit.ly/3HORkpz)

## IX. ការប្រមើលមើលពីសេរីភាពនិងឯករាជ្យភាពប្រព័ន្ធផ្សព្វផ្សាយ៖ រឿងរ៉ាវពីតំបន់អាស៊ីអាគ្នេយ៍ (សេចក្តីរាយការណ៍របស់ New Naratif)

*ការប្រមើលមើលពីសេរីភាពនិងឯករាជ្យភាពប្រព័ន្ធផ្សព្វផ្សាយ៖ រឿងរ៉ាវពីតំបន់អាស៊ីអាគ្នេយ៍កើតមាននៅក្នុងឆ្នាំដែលពោរពេញដោយបញ្ហាប្រឈមសម្រាប់សេរីភាពសារព័ត៌មាននៅតំបន់អាស៊ីអាគ្នេយ៍។*

*អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (RSF) បានកត់ត្រាថា អ្នកកាសែតយ៉ាងហោចណាស់៧៦នាក់ ត្រូវបានឃុំខ្លួនក្នុងពន្ធនាគារ និងម្នាក់ត្រូវបានសម្លាប់នៅក្នុងតំបន់ នៅឆ្នាំនេះ ហើយសន្ទស្សន៍សេរីភាពសារព័ត៌មានទូទាំងពិភពលោករបស់អង្គការនេះ បានដាក់ប្រទេសចំនួន១០ក្នុងចំណោមប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ទាំង១១ស្ថិតក្នុងចំណោមប្រទេស១០០ ដែលមានកម្រិតសេរីភាពសារព័ត៌មានទាបបំផុត ដោយប្រទេស ឡាវ ប្រ៊ុយណេ សិង្ហបុរី និងវៀតណាមស្ថិតនៅក្រោមលេខរៀងទី១៥០ ក្នុងចំណោម១៨០ប្រទេស ខណៈទីម័រខាងកើតគឺជាប្រទេសតែមួយគត់ដែលជាប់ចំណាត់ថ្នាក់នៅលើលេខរៀងទី១០០។*

*ទោះជាយ៉ាងណាក៏ដោយ សន្ទស្សន៍ទ្រង់ទ្រាយធំនេះបង្ហាញឲ្យយើងឃើញត្រឹមតែផ្នែកខ្លះនៃបញ្ហាប្រឈមទាក់ទិនសេរីភាពប្រព័ន្ធផ្សព្វផ្សាយនៅតំបន់អាស៊ីអាគ្នេយ៍ប៉ុណ្ណោះដោយមើលរំលងរឿងរ៉ាវច្រើននៅក្នុងតំបន់ក៏ដូចជាភាពសកម្មជាច្រើនទៀតរបស់អ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។*

*បញ្ហាបែបនេះ មិនមែនកើតមានតែនៅតំបន់អាស៊ីអាគ្នេយ៍នោះទេ បុគ្គលិកប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតក៏ជួបប្រទះបញ្ហាផ្សេងៗគ្នាដែរ។ បុគ្គលិកប្រព័ន្ធផ្សព្វផ្សាយឯករាជ្យបានក្លាយជាគោលដៅនៃការវាយប្រហារជាប្រចាំពីសំណាក់រដ្ឋាភិបាលនៅតំបន់អាស៊ីអាគ្នេយ៍ ដែលជំរុញឲ្យយើងទាំងអស់គ្នាស្វែងយល់បន្ថែមទៀតពីបញ្ហាដែលពួកគេប្រឈមមុខ។ ប្រភព ៖* https://bit.ly/3nZ9ZHK

## X. ទិវាសិទ្ធិមនុស្ស៖ អ្នកសារព័ត៌មានចំនួន៤៥នាក់ត្រូវបានសម្លាប់នៅទូទាំងពិភពលោកក្នុងឆ្នាំ២០២១ និង៣៦៥ នាក់កំពុងជាប់ពន្ធនាគារនៅឡើយ

*ដើម្បីអបអរទិវាសិទ្ធិមនុស្សអន្តរជាតិថ្ងៃទី១០ ខែធ្នូ សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ (IFJ) បានចេញផ្សាយបញ្ជីឈ្មោះអ្នកសារព័ត៌មានដែលត្រូវបានចាប់ដាក់ពន្ធនាគារនិងត្រូវបានគេសម្លាប់នៅក្នុងឆ្នាំ២០២១។*

*យោងតាមស្ថិតិរបស់សហព័ន្ធនេះបានឲ្យដឹងថា អ្នកសារព័ត៌មាន៤៥នាក់ត្រូវបានគេសម្លាប់ចាប់តាំងពីថ្ងៃទី១ ខែមករាឆ្នាំ២០២១ ហើយ៣៦៥នាក់កំពុងជាប់ក្នុងពន្ធនាគារនៅឡើយ។*

*តារាងស្ថិតិទាំងពីរនេះបានគូសបញ្ជាក់ពីវិបត្តិដ៏ធ្ងន់ធ្ងរក្នុងវិស័យសារព័ត៌មាននៅពេលសិទ្ធិនិងសេរីភាពរបស់អ្នកសារព័ត៌មានរងការគំរាមកំហែងជាបន្តបន្ទាប់នៅក្នុងតំបន់ជាច្រើនទូទាំងពិភពលោក។*

*យោងតាមតារាងស្ថិតិទាំងពីររបស់ IFJ អំពីចំនួនអ្នកកាសែតដែលត្រូវបានសម្លាប់ និងជាប់ពន្ធនាគារ គឺអ្នកកាសែតចំនួន៣៦៥នាក់នៅបន្តជាប់ក្នុងពន្ធនាគារនៅឡើយគិតត្រឹមថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ ពោលគឺមានកើនឡើង បើធៀបនឹងឆ្នាំមុនដែលមាន២៣៥នាក់។ ចិន (១០២) ទួរគី (៣៤) បេឡារុស្ស (២៩) អេរីទ្រា (២៩) អេហ្ស៊ីប (២៧) វៀតណាម (២១) មីយ៉ាន់ម៉ា (១៨) រុស្ស៊ី (១២) អាហ្សែបៃហ្សង់និងយេម៉ែន (១១) កម្ពុជា (១០) និងអ៊ីរ៉ង់ (៩) គឺជាប្រទេសដែលឃុំខ្លួនអ្នកសារព័ត៌មានច្រើនបំផុត។*

*ការបង្ក្រាបលើអ្នកជំនាញប្រព័ន្ធផ្សព្វផ្សាយនៅក្នុងរបបផ្តាច់ការ រួមទាំងការចាប់ខ្លួនអ្នកសារព័ត៌មានយ៉ាងច្រើននៅក្នុងប្រទេសមីយ៉ាន់ម៉ា បេឡារុស្ស អាហ្សែបៃហ្សង់ និងហុងកុងគឺជាមូលហេតុបណ្តាលឲ្យចំនួនអ្នកសារព័ត៌មានជាប់ពន្ធនាគារកើនឡើងជាបន្តបន្ទាប់នៅពេលបច្ចុប្បន្ននេះ។ ប្រភព ៖* https://bit.ly/3u1hL7S

## XI. និន្នាការពិភពលោកជុំវិញសេរីភាពនៃការបញ្ចេញមតិនិងការអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន (យូណេស្កូ)

*វិជ្ជាជីវៈសារព័ត៌មានរងការរិះគន់ទូទាំងពិភពលោក។ ខណៈដែលមនុស្សកាន់តែច្រើនអាចទទួលបានមាតិកាព័ត៌មានច្រើនជាងពេលមុនៗ ការខ្វែងគំនិតផ្នែកនយោបាយបូករួមទាំងការផ្លាស់ប្តូរបច្ចេកវិទ្យាបានជួយសម្រួលដល់ការផ្សព្វផ្សាយពាក្យសំដីបង្កប់ភាពស្អប់ខ្ពើម ភាពស្អប់ខ្ពើមចំពោះស្ត្រីនិងការផ្សព្វផ្សាយព័ត៌មានមិនពិត និងគ្មានការបញ្ជាក់បានឆាប់រហ័ស ហើយជារឿយៗនាំឲ្យមានការរឹតត្បិតហួសប្រមាណលើសេរីភាពនៃការបញ្ចេញមតិ។*

*ភាគច្រើននៃបណ្តាប្រទេសទាំងនោះ អ្នកសារព័ត៌មានប្រឈមមុខនឹងការវាយប្រហារទាំងផ្លូវកាយនិងពាក្យសម្តី ដែលគំរាមកំហែងដល់លទ្ធភាពក្នុងការរាយការណ៍ដំណឹងនិងព័ត៌មានដល់សាធារណជន។*

*ដោយប្រឈមមុខនឹងបញ្ហាប្រឈមបែបនេះ និន្នាការពិភពលោកស្តីពីសេរីភាពនៃការបញ្ចេញមតិនិងការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយផ្តល់នូវការវិភាគបែបស៊ីជម្រៅអំពីនិន្នាការនៃសេរីភាពសារព័ត៌មានពហុនិយមឯករាជ្យភាពនិងសុវត្ថិភាពរបស់អ្នកសារព័ត៌មាន។*

*របាយការណ៍សកល (ចេញផ្សាយរៀងរាល់ប្រាំឆ្នាំម្តង) រួមជាមួយនឹងឯកសារសង្ខេប និងការបោះពុម្ពផ្សាយពាក់ព័ន្ធផ្សេងទៀតផ្តល់នូវទស្សនវិស័យកម្រិតម៉ាក្រូ ដែលបំពេញតួនាទីជាធនធានដ៏សំខាន់សម្រាប់រដ្ឋសមាជិករបស់អង្គការយូណេស្កូ អង្គការអន្តរជាតិ ក្រុមសង្គមស៊ីវិល ការសិក្សានិងបុគ្គលដែលចង់ស្វែងយល់អំពីការផ្លាស់ប្តូរទម្រង់ប្រព័ន្ធផ្សព្វផ្សាយជាសកល។ ប្រភព ៖* https://bit.ly/3g4MSa9

ខេមបូចា

CamboJA

សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា

*Cambodian Journalists Alliance Association*

គាំទ្រមូលនិធិដោយ

Sweden Sverige

# ទំនាក់ទំនង


+855 (0)23 88 23 11

communications@camboja.net

ផ្ទះលេខ១៩ ផ្លូវ៣៨៨ សង្កាត់ទួលស្វាយព្រៃ១
ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ